ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :...១៦៧.........បទ..ប្រក..

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងការតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស ( DIX )

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ៦៦អនក្រ.បក ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ ស្តីពីការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ១៨១អនក្រ.បកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញសារាចរអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ប្រៃសណីយ៍និងទូរគមនាគមន៍ លេខ ១២៧៧ ស.ហ.វ - ប.ទ. ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០០៩ ស្តីពីវិធានការទប់ស្កាត់ភាពពុំស្មោះត្រង់នៃការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍,
- បានឃើញប្រកាសលេខ ២០៦ ប.ទប្រក. ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩ ស្តីពីការតភ្ជាប់បណ្តាញទូរគមនាគមន៍,

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ

ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០

ទូរសារ: (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១

- បានឃើញប្រកាសលេខ ១០៩ ប.ទ. ចុះថ្ងៃទី១០ខែមិថុនាឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**សម្រេច**

## ប្រការ ១ : គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់ល័ក្ខខ័ណ្ឌក្នុងការគ្រប់គ្រងការតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស ( Domestic Internet Exchange «DIX » ) ដោយផ្អែកលើកត្តាខាងក្រោម៖

- ធ្វើឱ្យការប្រើប្រាស់អ៊ីនធឺណេតមានលក្ខណៈសន្សំសំចៃតាមរយៈការបង្វែរផ្លូវអ៊ីនធឺណេតក្នុងប្រទេសដោយមិនចាំបាច់តភ្ជាប់ទៅក្រៅប្រទេសឱ្យមកតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស(Domestic Internet Exchange«DIX») វិញ។
- បង្កើនការប្រើប្រាស់អ៊ីនធឺណេតក្នុងប្រទេសឱ្យមានល្បឿនលឿនជាមួយនឹងថ្លៃទាបសមរម្យផ្តល់អត្ថប្រយោជន៍ជូនសាធារណជន។
- កាត់បន្ថយហានិភ័យដោយបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងសុវត្ថិភាពលើបណ្តាញអ៊ីនធឺណេត។

## ប្រការ ២ : និយមន័យ

ពាក្យបច្ចេកទេសទាំងឡាយដែលប្រើក្នុងប្រកាសនេះមានន័យដូចតទៅ៖

១) **ការតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស** ( Domestic Internet Exchange - DIX )

សំដៅលើការតភ្ជាប់អ៊ីនធឺណេតក្នុងប្រទេសដែលបង្កលក្ខណៈឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេត (ISP) ទាំងអស់អាចតភ្ជាប់អ៊ីនធឺណេតបាន។

២) **អ៊ីនធឺណេត ណូដ** (Internet Node / DIX Node)

សំដៅលើប្រព័ន្ធកុំព្យូទ័រដែលមានមូលដ្ឋានបច្ចេកទេសក្នុងព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវកំណត់នូវ IP Address របស់ប្រទេសកម្ពុជាដែលអាចតភ្ជាប់បណ្តាញនៅក្នុងប្រទេសនិងទៅអន្តរជាតិបាន។

៣) **បញ្ជូរបង់** (Bandwidth)

សំដៅលើទំហំទិន្នន័យបញ្ជូនទៅមកក្នុងបណ្តាញមួយដោយគិតខ្នាតជា Bit ក្នុងមួយវិនាទី ( Bit Per Second – bps )។

៤) ត្រាហ្វិក (Traffic)

សំដៅលើបរិមាណនៃការប្រើប្រាស់អ៊ីនធឺណេត។

៥) មជ្ឈមណ្ឌលទិន្នន័យ (Data Center)

សំដៅលើមជ្ឈមណ្ឌលកុំព្យូទ័រដែលផ្ទុកពល់ទិន្នន័យទូរគមនាគមន៍។

៦) ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេត (Internet Service Provider - ISP)

សំដៅលើប្រតិបត្តិករផ្គត់ផ្គង់សេវាអ៊ីនធឺណេតជូនអតិថិជនតាមការតភ្ជាប់បណ្តាញផ្ទាល់។

៧) ពិធីសារអ៊ីនធឺណេត (Internet Protocol - IP)

សំដៅលើរបៀបរបបបញ្ជូនទិន្នន័យទៅមកដោយប្រើ Packet – Switched ឆ្លងកាត់ក្នុងបណ្តាញតាមទម្រង់បច្ចេកទេសអ៊ីនធឺណេត (TCP/IP)។

៨) ពិធីសារបញ្ជាការបញ្ជូន (Transmission Control Protocol - TCP)

សំដៅលើនិយាមបច្ចេកទេសអ៊ីនធឺណេតដែលជាកាតព្វកិច្ចត្រូវប្រើសម្រាប់គ្រប់បណ្តាញដើម្បីតភ្ជាប់ទៅកាន់អ៊ីនធឺណេត។

៩) លេខប្រព័ន្ធស្វ័យភាព (Autonomous System Number – ASN)

សំដៅលើលេខសម្គាល់តែមួយគត់សម្រាប់ប្រើប្រាស់តភ្ជាប់បណ្តាញអ៊ីនធឺណេតដោយត្រង់ទៅមកជាលក្ខណៈ Peering។

១០) ភៀរីង (Peering)

សំដៅលើការតភ្ជាប់គ្នាទៅវិញទៅមកដោយស្ម័គ្រចិត្តរវាងបណ្តាញអ៊ីនធឺណេតដែលគ្រប់គ្រងដោយឡែកពីគ្នា។

១១) អង្គបែងចែកផ្លូវអ៊ីនធឺណេត (IP Router)

សំដៅលើឧបករណ៍កំណត់ផ្លូវសម្រាប់ភ្ជាប់និងចែកចាយអ៊ីនធឺណេតរវាងក្រុមហ៊ុន DIX និង ក្រុមហ៊ុន ISPs។

១២) អាសយដ្ឋាន IP (IP Addresses)

សំដៅលើលេខអាសយដ្ឋានកំណត់ឱ្យឧបករណ៍នីមួយៗសម្រាប់ចូលក្នុងបណ្តាញកុំព្យូទ័រមួយដោយប្រើប្រាស់ពិធីសារអ៊ីនធឺណេត ( IP )។

១៣) បមាណីអ៊ីនធឺណេត (Internet Switch)

សំដៅលើឧបករណ៍សម្រាប់ចែកចាយអ៊ីនធឺណេតនៅក្នុងបណ្តាញតាមគោលដៅសម្រាប់បញ្ជូនកញ្ចប់នៃពិធីសារអ៊ីនធឺណេត។

១៤) ខុនថេន (Content)

សំដៅលើមណ្ឌលធនធានព័ត៌មានដាក់បង្ហាញលើទំព័រអ៊ីនធឺណេតដែលអតិថិជនអាចបើកមើលតាមត្រូវការ។

១៥) បញ្ញត្តិករ

សំដៅលើក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានភារកិច្ចបង្កើត និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានទាំងឡាយទាក់ទងនឹងវិស័យទូរគមនាគមន៍ រហូតដល់បញ្ញត្តិករទូរគមនាគមន៍កម្ពុជាបានបង្កើតឡើង។

## ប្រការ ៣ : គោលការណ៍ទូទៅ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសិទ្ធិផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនផ្តល់សេវាតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស (DIX)។ ការផ្តល់អាជ្ញាប័ណ្ណត្រូវធ្វើឡើងស្របតាមការចាំបាច់និងការរីកចម្រើននៃទីផ្សារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ក្នុងពេលធ្វើប្រតិបត្តិការអាជីវកម្ម ក្រុមហ៊ុនផ្តល់សេវាតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស (DIX) ត្រូវ៖

- មានអាជ្ញាប័ណ្ណ,
- ផ្តល់សេវាដោយអព្យាក្រឹតនិងពុំមែនជាអ្នកផ្តល់សេវាដទៃទេក្រៅពីសេវាតភ្ជាប់បណ្តាញអ៊ីនធឺណេតក្នុងប្រទេស (DIX)។
- ធ្វើអាជីវកម្មផ្អែកលើមូលដ្ឋានថ្លៃសេវាដែលមានការយល់ព្រមពីភាគីតភ្ជាប់ជាសមាជិក។
- ចៀសវាងដោយដាច់ខាតនូវការបន្ទុចបង្អាក់ លបស្តាប់ ថតចម្លង កត់ត្រា ឬ វិភាគទិន្នន័យណាមួយដែលឆ្លងកាត់តាមបណ្តាញរបស់ខ្លួន។
- គោរពតាមការណែនាំរបស់បញ្ញត្តិករដូចមានចែងក្នុងបទប្បញ្ញត្តិ និងអាជ្ញាប័ណ្ណក្នុងន័យបម្រើផលប្រយោជន៍ជូនភាគីតភ្ជាប់ជាសមាជិកទាំងអស់ដោយមិនរើសអើង។
- មានកាតព្វកិច្ចភ្ជាប់បណ្តាញ IP ជាមួយក្រុមហ៊ុន DIX ដទៃទៀតដោយមានចុះកិច្ចសន្យាត្រឹមត្រូវ ដើម្បីរក្សាសុវត្ថិភាពបណ្តាញនិងការបញ្ជូនត្រាហ្វិកទៅមកដោយមានគុណភាពល្អ។

## ប្រការ ៤ : សិទ្ធិរបស់ភាគីតភ្ជាប់

ភាគីតភ្ជាប់ដែលតភ្ជាប់បណ្តាញរបស់ខ្លួនទៅនឹង DIX មានសិទ្ធិ ៖

- ជ្រើសរើសការតភ្ជាប់បណ្តាញរបស់ខ្លួនទៅនឹងក្រុមហ៊ុន DIX ដែលមានគុណភាព សុវត្ថិភាពនិងប្រតិបត្តិការ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍។ ភាគីតភ្ជាប់អាចតភ្ជាប់បណ្តាញជាមួយនឹងភាគីតភ្ជាប់ដទៃទៀត ដោយផ្អែកលើល័ក្ខខ័ណ្ឌនៃការចរចាជាលក្ខណៈពាណិជ្ជកម្មនិងដោយគ្មានការរើសអើង។
- ចែកចាយនិងទទួលត្រាហ្វិកក្នុងប្រទេសជាមួយសមាជិកទាំងអស់របស់ក្រុមហ៊ុន DIX ដោយគ្មានរើសអើង។

## ប្រការ ៥ : ភាតព្វកិច្ចរបស់ភាគីតភ្ជាប់និងក្រុមហ៊ុន DIX

- ភាគីតភ្ជាប់ដែលជាសមាជិកត្រូវផ្តល់ឱ្យក្រុមហ៊ុន DIX នូវទំហំទិន្នន័យ ត្រាហ្វិក ប៉ាន់ស្មានព្រមទាំងទិន្នន័យបច្ចេកទេសចាំបាច់និងសមស្របសម្រាប់ឱ្យក្រុមហ៊ុន DIX មានលទ្ធភាពប្រតិបត្តិមុខនាទីរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។
- ក្រុមហ៊ុន DIX ត្រូវជានានិងរក្សាការសម្ងាត់ចំពោះរាល់ទិន្នន័យដែលភាគីតភ្ជាប់ជាសមាជិកផ្តល់ឱ្យ សម្រាប់ធ្វើជាកម្មវត្ថុឆ្លើយបញ្ជាក់ជូនមកបញ្ញត្តិករតាមការចាំបាច់។
- ក្រុមហ៊ុន DIX ត្រូវប្រើប្រាស់ទិន្នន័យដែលភាគីតភ្ជាប់បានផ្តល់ឱ្យ ដោយគោរពប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួនតាមបទដ្ឋានបច្ចេកទេសរបស់សហភាពទូរគមនាគមន៍អន្តរជាតិ ( ITU )និងនិយាមអន្តរជាតិព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានចែងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៦ : ល័ក្ខខ័ណ្ឌនៃការតភ្ជាប់បណ្តាញ

- ក្រុមហ៊ុន DIX ត្រូវមានសម្ភារៈឧបករណ៍សម្រាប់សម្របសម្រួលដំណើរការឱ្យបានគ្រប់គ្រាន់ ដើម្បីតភ្ជាប់បណ្តាញអ៊ីនធឺណេតគ្រប់ប្រភេទដូចមានចែងក្នុងអាជ្ញាប័ណ្ណ។
- ភាគីតភ្ជាប់ដែលនៅក្នុងតំបន់ណាមួយអាចប្រមូលផ្តុំត្រាហ្វិកចេញពីភាគីតភ្ជាប់ផ្សេងទៀតនៅក្នុងតំបន់ហើយភ្ជាប់ទៅកាន់ក្រុមហ៊ុន DIX ដោយឆ្លងកាត់តាមការតភ្ជាប់តែមួយ។
- ឧបករណ៍ DIX Router គ្រាន់តែសម្រាប់ផ្លាស់ប្តូរព័ត៌មានប៉ុណ្ណោះ ហើយពុំទទួលយកត្រាហ្វិកឆ្លងកាត់ (Transit traffic) ណាមួយទេ។

- ឧបករណ៍ DIX Router នឹងធានាភាពប់រងចំពោះការផ្លាស់ប្តូរត្រាហ្វិកក្នុងតំបន់ដែលមាននៅក្នុងវង្វង់ DIX។ការងារនេះត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពពីគ្រប់សមាជិកពហុទ្វេភាគីដែលមាននៅក្នុងតំបន់ DIXរបស់ខ្លួន។

- ក្រុមហ៊ុនផ្តល់សេវា content និង មជ្ឈមណ្ឌលទិន្នន័យទាំងឡាយក៏អាចតភ្ជាប់បណ្តាញទៅក្រុមហ៊ុន DIX បានដែរ។ ដើម្បីរៀបចំដំឡើងផ្លូវ ( Route ) តភ្ជាប់ទៅក្រុមហ៊ុន DIX ក្រុមហ៊ុនផ្តល់សេវា content និង មជ្ឈមណ្ឌលទិន្នន័យត្រូវៈ

ក ) មានលេខប្រព័ន្ធស្វ័យភាព (ASN) ផ្ទាល់ខ្លួន,

ខ ) មានអាសយដ្ឋាន IP ដើម្បីបង្កើតជាផ្លូវតភ្ជាប់បណ្តាញជាមួយគ្នា។

គ ) ចៀសវាងដាច់ខាតនូវការបញ្ជូនត្រាហ្វិកឆ្លងកាត់ DIX ដោយមានដាក់បញ្ចូលនូវមាតិកាអាសអាភាសឬផ្សព្វផ្សាយល្បែងស៊ីសងដែលផ្ទុយនឹងប្រពៃណីទំនៀមទម្លាប់ជាតិនិងច្បាប់ជរមាននៃព្រះរាជាណាចក្រកម្ពុជា។

- ប្រតិបត្តិករទូរគមនាគមន៍ដែលបានជួលជាវចំណុះ Bandwidth ( leased bandwidth ) ឱ្យក្រុមហ៊ុន ISPs ឬ ភាគីតភ្ជាប់ដទៃ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការតភ្ជាប់បណ្តាញទៅនឹងក្រុមហ៊ុន DIX ស្របតាមខ្លឹមសារនៃប្រការ៤ខាងលើ។

## ប្រការ ៧ : គុណភាពនៃសេវា

- ក្រុមហ៊ុន DIX ត្រូវដំណើរការនិងរក្សាគុណភាពថាមពលឱ្យដល់ ៩៩% គ្រប់ពេលវេលានិងគ្រប់ទីកន្លែង ពោលគឺត្រូវមានថាមពលត្រៀមបម្រុងឱ្យគ្រប់គ្រាន់ ( ត្រូវមានម៉ាស៊ីនភ្លើងត្រៀមបម្រុង )។

- ក្រុមហ៊ុន DIX ត្រូវជូនដំណឹងទៅគ្រប់ភាគីតភ្ជាប់ជាសមាជិកយ៉ាងតិច៧ថ្ងៃមុនពេលចាប់ផ្តើមដំណើរការជួសជុល ឬ ដោះស្រាយបញ្ហានានាដែលបណ្តាលឱ្យមានការរំខានដល់ត្រាហ្វិក។

- បរិក្ខារ DIX Router មិនត្រូវរារាំង ឬ ទប់ស្កាត់ត្រាហ្វិក ហើយក៏ពុំត្រូវអូសបន្លាយពេលវេលាដោយប្រការណាមួយឡើយ។

- ក្រុមហ៊ុន DIX ត្រូវធានាការពារបរិស្ថានឱ្យបានស្អាតល្អ និង រក្សាកម្រិតសីតុណ្ហភាព ព្រមទាំងបំពាក់ប្រព័ន្ធការពារសុវត្ថិភាព (អគ្គីភ័យ, រន្ទះ) ឱ្យស្របតាមបទដ្ឋានបច្ចេកទេសនៃបរិក្ខារ DIX។

- ដើម្បីធានាសុវត្ថិភាព គុណភាពនិងប្រសិទ្ធភាពរបស់បរិក្ខារ DIX ត្រាហ្វិករបស់ភាគីតភ្ជាប់ដែលតភ្ជាប់ទៅបរិក្ខារ DIX ពុំត្រូវលើសពី ៨០% នៃចំណុះសរុប

របស់បណ្ដាញតភ្ជាប់ក្នុងរយៈពេល ២៤ ម៉ោងសម្រាប់ ១ ថ្ងៃ និង ៧ ថ្ងៃក្នុង ១ សប្ដាហ៍ឡើយ។

- ក្រុមហ៊ុន DIX មានសិទ្ធិត្រួតពិនិត្យត្រាហ្វិក រួចជូនដំណឹងទៅគ្រប់ភាគីតភ្ជាប់ជាសមាជិកអំពីតម្រូវការពង្រីក Bandwidth ឱ្យស្របតាមកំណើននៃទំហំត្រាហ្វិកក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

## ប្រការ ៨ : ការដោះស្រាយវិវាទ

- ក្នុងករណីមានវិវាទកើតឡើងរវាងក្រុមហ៊ុន DIX ជាមួយភាគីតភ្ជាប់ដែលជាសមាជិករបស់ខ្លួន ភាគីមានវិវាទត្រូវដោះស្រាយតាមនីតិវិធីដោយឈរលើកិច្ចសន្យាជរមាន។

- ក្នុងករណីពុំអាចដោះស្រាយបាន ភាគីមានវិវាទអាចដាក់ពាក្យស្នើសុំដោះស្រាយមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដោយភ្ជាប់មកជាមួយនូវៈ

  + ឯកសារស្នើសុំដោះស្រាយវិវាទ,
  + ឯកសារសេដ្ឋកិច្ច បច្ចេកទេស និងភស្តុតាងដែលពាក់ព័ន្ធ,
  + សំណូមពរ ( ប្រសិនបើមាន )។

- អាសយដ្ឋានទទួលឯកសារ :

  + ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កាច់ជ្រុងផ្លូវលេខ១១៣និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

    អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ :

    ◎ ទូរស័ព្ទលេខ : ០១២ ៧៦ ៧៧ ៧៥

    ◎ ទូរសារលេខ: ០២៣ ៧២ ២៩ ៨១

    ◎ Email : sokharathpenh@gmail.com។

- នីតិវិធីដោះស្រាយវិវាទ :

  + ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចសម្រេចពុំទទួលដោះស្រាយ ឬ ទទួលដោះស្រាយវិវាទក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

  + ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងឆ្លើយតបជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់លាស់អំពីមូលហេតុពុំទទួលដោះស្រាយវិវាទ និងផ្ដល់អនុសាសន៍ណែនាំ ( ប្រសិនបើមាន ) ក្នុងករណីពិនិត្យឃើញថា កម្មវត្ថុដែលលើកឡើងនៅក្នុងឯកសារមិនស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន។

\+ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចសម្រេចដោះស្រាយវិវាទក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានគ្រប់គ្រាន់និងស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន។ ការដោះស្រាយវិវាទត្រូវអនុវត្តជាជំហានៗដូចតទៅ៖

ជំហានទី១

ក្នុងករណីចាំបាច់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងបង្កើតក្រុមបេសកកម្មចុះពិនិត្យលើកម្មវត្ថុវិវាទនិងវាស់វែងតាមជាក់ស្តែងដើម្បីវាយតម្លៃនិងកំណត់មូលហេតុឱ្យបានច្បាស់លាស់។

ភាគីដែលពាក់ព័ន្ធនឹងការតភ្ជាប់បណ្តាញអ៊ីនធឺណេតត្រូវផ្តល់ទិន្នន័យគ្រប់គ្រាន់និងទាន់ពេលវេលាផ្តល់ឧបករណ៍ព្រមទាំងចាត់អ្នកឯកទេសឱ្យចូលរួមជាមួយក្រុមត្រួតពិនិត្យ ប្រសិនបើមានការស្នើសុំ។

ជំហានទី២

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចសម្របសម្រួលឱ្យមានការចរចាជាមួយភាគីពាក់ព័ន្ធ។

ជំហានទី៣

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងចេញសេចក្តីជូនដំណឹង ឬសេចក្តីសម្រេចដោះស្រាយវិវាទ។

ជំហានទី៤

ភាគីមានវិវាទត្រូវអនុវត្តតាមខ្លឹមសារទាំងឡាយដែលមានចែងនៅក្នុងសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចដោះស្រាយវិវាទ។

## ប្រការ ៩ : លក្ខខណ្ឌនៃការផ្តល់របាយការណ៍

ក្រុមហ៊ុន DIX មានភារកិច្ចផ្តល់របាយការណ៍អំពីប្រតិបត្តិការរបស់ខ្លួនជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យបានទៀងទាត់នៅរៀងរាល់ដំណាច់ត្រីមាសនីមួយៗ។

## ប្រការ ១០: វិធានការ

ប្រសិនបើរូបវន្តបុគ្គល នីតិបុគ្គលណាក្លែងបន្លំ ប្រព្រឹត្តល្មើសឬធ្វើសកម្មភាពផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងចាត់វិធានការដូចតទៅ៖

ទី ១ ) ព្យួរអាជ្ញាប័ណ្ណបណ្តោះអាសន្ន,

ទី ២ ) ក្នុងករណីពុំរាងចាល ដកហូតអាជ្ញាប័ណ្ណជាស្ថាពរ រួចប្តឹង

ទៅតុលាការ។

ប្រការ ១១ : បណ្ដាក្រុមហ៊ុនផ្ដល់សេវាតភ្ជាប់បណ្ដាញអ៊ីនធឺណេតក្នុងប្រទេស (DIX) ដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវគោរពប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួនតាមខ្លឹមសារទាំងឡាយនៃប្រកាសនេះ។

ប្រការ ១២ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាល់ប្រកាសនិងលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រកាសនេះអាចនឹងកែប្រែតាមករណីចាំបាច់។

ប្រការ ១៣ : ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានចំណុះក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បណ្ដាមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ គ្រប់ក្រុមហ៊ុនផ្ដល់សេវាតភ្ជាប់បណ្ដាញអ៊ីនធឺណេតក្នុងប្រទេស (DIX) រាល់ក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណេត(ISP) និង ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមខ្លឹមសារនៃប្រកាសនេះ។ ៨ ក.ខ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១១

រដ្ឋមន្ត្រី

សូ ខុន

កន្លែងទទួល :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

« ដើម្បីជូនជ្រាប »

- ដូចប្រការ ១៣ « ដើម្បីអនុវត្ត »
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ ៨